Washington State Office of the Attorney General

# ការអនុវត្តប្រសើរបំផុត សម្រាប់ការរាយការណ៍ ការស៊ើបអង្កេត និងការ ត្រួតពិនិត្យលើការប្រើកម្លាំង

ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2022

# ការអនុវត្តប្រសើរបំផុតសម្រាប់ការរាយការណ៍ ការស៊ើបអង្កេត និងការត្រួតពិនិត្យលើការប្រើកម្លាំង

**<u>គោលការណ៍ស្នូល៖</u> ដើម្បីទទួលខុសត្រូវចំពោះសាធារណជន និងវាយតម្លៃតម្រូវការបណ្តុះបណ្តាល និងការអភិវឌ្ឍគោលការណ៍ អង្គភាព រាល់ការប្រើកម្លាំងកាយនិងកម្លាំងគ្រោះថ្នាក់ដល់ជីវិត ក៏ដូចជាករណីភ្ជង់កាំភ្លើងដល់បុគ្គលណាម្នាក់ ត្រូវរាយការណ៍លក្ខណៈផ្ទៃក្នុង និងទទួលការពិនិត្យវាយតម្លៃប្រកបដោយអត្តន័យពីមន្ត្រីផ្នែកបញ្ជាការ។**

**អង្គភាពក៏មានភារកិច្ចរាយការណ៍ការប្រើប្រាស់កម្លាំងជាក់លាក់ទៅកម្មវិធីទិន្នន័យប្រើកម្លាំងទូទាំងរដ្ឋផងដែរ [សូមមើល Revised Code of Washington (RCW, ក្រមដែលបានកែប្រែនៃរដ្ឋវ៉ាស៊ីនតោន) 10.118.030 ដើម្បីដឹងពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍]។**

# ការរាយការណ៍ការប្រើប្រាស់កម្លាំង

(1) មន្ត្រីអាជ្ញាធរត្រូវជូនដំណឹងដល់ប្រធានមន្ត្រីរបស់ខ្លួនភ្លាមៗ ក្រោយពេលប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិត ឬកម្លាំងកាយ។ ភារកិច្ចនេះអនុវត្តចំពោះមន្ត្រីអាជ្ញាធរដែលបានប្រើកម្លាំង។ មន្ត្រីអាជ្ញាធរទាំងឡាយដែលបានឃើញការប្រើកម្លាំងក៏ត្រូវប្រាកដថា កម្លាំងនោះត្រូវបានរាយការណ៍ទៅប្រធានមន្ត្រីផងដែរ។ ភារកិច្ចជូនដំណឹងទៅប្រធានមន្ត្រីក្រោយពេលប្រើកម្លាំងរួមមាន ការត្អូញត្អែរឬការចោទប្រកាន់ពីបទប្រើកម្លាំងជ្រុលហួសឬមិនសមស្របពីបុគ្គលរងការប្រើកម្លាំង ឬអ្នកផ្សេងទៀត។

(2) លើកលែងតែការប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិត ដែលអង្គភាពអាចមានពិធីការសរសេររបាយការណ៍សម្រាប់ហេតុការណ៍ប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិត មន្ត្រីអាជ្ញាធរដែលប្រើកម្លាំងកាយ ឬមានវត្តមាននៅកន្លែងកើតហេតុដែលកម្លាំងកាយត្រូវបានប្រើ ត្រូវដាក់បញ្ជូនរបាយការណ៍អំពីការប្រើកម្លាំងមុនពេលបញ្ចប់វេន លុះត្រាតែស្ថិតក្នុងកាលៈទេសៈដែលអាចយោគយល់ ដូចជាមន្ត្រីនោះរងរបួសជាដើម ទើបអាចមិនធ្វើដូច្នេះបាន។ កាលៈទេសៈសម្រាលទោសដែលពន្យារពេលធ្វើរបាយការណ៍ប្រើកម្លាំងត្រូវតែកត់ត្រាទុក។

   (a) ការភ្ជង់កាំភ្លើងដាក់បុគ្គលណាម្នាក់គឺជាការប្រើកម្លាំងដែលត្រូវរាយការណ៍។

   (b) ការវាយខ្នោះដោយអនុលោមតាមច្បាប់មិនចាំបាច់រាយការណ៍ទេ ប៉ុន្តែមន្ត្រីអាជ្ញាធរត្រូវតែកត់ត្រាទុកនៅពេលដែលការប្រើខ្នោះបណ្តាលឱ្យមានការឈឺចាប់ ក៏ដូចជារលាត់ស្បែក រយះសាច់ ស្នាមជាំ ឬរបួសផ្សេងទៀតដោយសារតែខ្នោះ ឬការវាយខ្នោះ។

(3) ខ្លឹមសាររបាយការណ៍

មន្ត្រីអាជ្ញាធរត្រូវបញ្ជាក់អង្គហេតុជាក់លាក់ ដើម្បីពន្យល់ពីការសម្រេចចិត្តប្រើកម្លាំងកាយឬកម្លាំងគ្រោះថ្នាក់ដល់ជីវិត និងប្រើឧបករណ៍ឬយុទ្ធសាស្ត្រប្រើកម្លាំងជាក់លាក់។ របាយការណ៍ត្រូវរៀបរាប់ឱ្យបានក្បោះក្បាយ ដោយពន្យល់សេចក្តីលម្អិតនៃហេតុការណ៍ ហើយជៀសវាងសរសេរឃ្លាស្រពេចស្រពិលឬទូទៅសម្រាប់សកម្មភាពដែលបានសង្កេត ដូចជា "បានធ្វើចលនាលាក់លៀម" ឬ "បានប្រើជំហរប្រយុទ្ធ" ជាដើម។

របាយការណ៍ការប្រើកម្លាំងត្រូវមានព័ត៌មានខាងក្រោម៖

   (a) សេចក្តីសង្ខេបអំពីហេតុការណ៍ដែលពន្យល់មូលហេតុប៉ះទង្គិចគ្នាដំបូងរវាងមន្ត្រីអាជ្ញាធរនិងបុគ្គលដែលរងការប្រើកម្លាំង សកម្មភាពរបស់មន្ត្រីអាជ្ញាធរនិងបុគ្គលនោះដែលឈានដល់ការប្រើកម្លាំងនិងអំឡុងពេលប្រើកម្លាំង ក៏ដូចជាប្រភេទនិងកម្រិតកម្លាំងជាក់លាក់ដែលបានប្រើ

   (b) កិច្ចខិតខំប្រឹងប្រែងបន្ថយភាពតានតឹងដែលបានប្រើឬបានព្យាយាមធ្វើ ឬមូលហេតុដែលមិនបានប្រើ ឬមិនបានព្យាយាមធ្វើ

   (c) មូលហេតុប្រើកម្លាំង និងប្រភេទកម្លាំងនីមួយៗ រួមមានជាអាទិ៍ ការគំរាមកំហែងមកលើមន្ត្រីអាជ្ញាធរ ឬបុគ្គលផ្សេងទៀត ឬមូលដ្ឋានក្នុងការជឿជាក់ថាបុគ្គលដែលរងការប្រើកម្លាំងកាយនោះមានបំពាក់អាវុធ

   (d) ថាតើមានជម្រើសប្រើកម្លាំង ឬមិនប្រើកម្លាំងផ្សេងទៀតឬអត់

   (e) របៀបដែលមន្ត្រីអាជ្ញាធរប្រាប់ពីអត្តសញ្ញាណរបស់ខ្លួន

   (f) ការព្រមានដែលបានធ្វើ និងពេលវេលាក្នុងការអនុវត្តតាម មុនពេលប្រើកម្លាំង ឬមូលហេតុមិនធ្វើការព្រមាន និងទុកពេលឱ្យ

   (g) ឈ្មោះ និងអង្គភាពរបស់មន្ត្រីអាជ្ញាធរធ្វើសកម្មភាព និងមន្ត្រីឃើញហេតុការណ៍

   (h) ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់សាក្សីជាជនស៊ីវិល

   (i) ស្ថានភាពរបស់មន្ត្រីអាជ្ញាធរនៅពេលកើតហេតុ (ឧ. ឯកសណ្ឋានឬសម្លៀកបំពាក់ធម្មតា យានជំនិះមានឬគ្មានស្លាកសញ្ញា ម្នាក់ឯងឬមានមន្ត្រីអាជ្ញាធរផ្សេងទៀត)

(j) ព័ត៌មានអំពីបុគ្គលដែលរងការប្រើកម្លាំង រួមមានឈ្មោះ អាយុ ភេទ ពូជសាសន៍ ជាតិពន្ធុ ប្រសិនបើដឹង
(k) ទំហំ និងមាឌរបស់បុគ្គលដែលរងការប្រើកម្លាំង ធៀបនឹងមន្ត្រីអាជ្ញាធរ
(l) ភស្តុតាងបញ្ជាក់ថាបុគ្គលរងការប្រើកម្លាំងកំពុងមានវិបត្តិផ្លូវឥរិយាបថ
(m) ព័ត៌មានផ្សេងទៀតអំពីអត្តចរិតនិងស្ថានភាពរបស់បុគ្គលដែលរងការប្រើកម្លាំង រួមទាំងថាតើគាត់មានផ្ទៃពោះ ជាអនីតិជន ឬមនុស្សពេញវ័យដែលងាយរងគ្រោះ មានលក្ខណៈខ្សោយឬពិការភាព ចេះភាសាអង់គ្លេសមានកម្រិត ឬមានកុមារនៅជាមួយឬអត់
(n) អង្គហេតុដែលគាំទ្រដល់សកម្មភាពឃុំឃាំង ចាប់ខ្លួន ឬអនុវត្តច្បាប់ នៅពេលដែលអាចធ្វើបាន
(o) ថាតើបានស្នើសុំធនធានបម្រុង ឬធនធានផ្សេងទៀតឬអត់ ហើយបើបានស្នើសុំ ពេលណាដែលទៅដល់
(p) ការរៀបរាប់អំពីរបួសឬការត្អូញត្អែរអំពីរបួសប្រាប់មន្ត្រីអាជ្ញាធរ បុគ្គលរងការប្រើកម្លាំង ឬសាក្សី
(q) ជំនួយផ្នែកវេជ្ជសាស្ត្រ និងការសង្គ្រោះបឋមដែលបានផ្តល់នៅកន្លែងកើតហេតុ ប្រសិនបើមន្ត្រីអាជ្ញាធរបានដឹង និង
(r) ការជូនដំណឹងទៅប្រធានមន្ត្រី និងថាតើប្រធានមន្ត្រីបានឆ្លើយតបទៅនឹងកន្លែងកើតហេតុឬអត់ ឬត្រូវបានពិគ្រោះមុនពេល ឬអំឡុងហេតុការណ៍ឬអត់។

(4) មន្ត្រីដែលប្រើ Electronic Control Weapon (ECW, អាវុធឆក់អគ្គិសនី) ក៏ត្រូវកត់ត្រាទុកផងដែរ៖
(a) ឈ្មោះក្រុមហ៊ុន ម៉ូដែល លេខស៊េរីរបស់អាវុធ ECW
(b) ចំនួនដងនៃការបើកដំណើរការអាវុធ ECW និងរយៈពេលប្រើសរុប
(c) ប្រភេទមុខងារដែលបានប្រើ (ផ្លែព្រួញ ឬធ្វើឱ្យស្រឡាំងកាំងក្នុងករណីមិនបានរំពឹងទុក)
(d) ទីតាំងដែលផ្លែព្រួញ/អាវុធ ECW បានប៉ះនឹងបុគ្គលនោះ និងប្រភេទសម្លៀកបំពាក់ដែលផ្លែព្រួញបានប៉ះ និង
(e) ព័ត៌មានដែលពាក់ព័ន្ធ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពអាវុធ (ឧ. ថាតើផ្លែព្រួញបានប៉ះមនុស្សឬអត់ បើអត់ទេ តើហេតុអ្វី - ឧ. សម្លៀកបំពាក់របស់បុគ្គលនោះសំពីងសំពោង បុគ្គលនោះនៅឆ្ងាយពេក។ល។)។

(5) មន្ត្រីឃើញហេតុការណ៍ត្រូវប្រាប់រឿងរ៉ាវដែលកត់ត្រាអំពីការសង្កេត និងសកម្មភាពរបស់ពួកគេ។

(6) អង្គភាពអនុវត្តន៍ច្បាប់ត្រូវផ្តល់ទិន្នន័យអំពីហេតុការណ៍ប្រើកម្លាំងកាយនិងកម្លាំងគ្រោះថ្នាក់ដល់ជីវិត ដែលតម្រូវដោយកម្មវិធីប្រមូលទិន្នន័យប្រើកម្លាំងទូទាំងរដ្ឋ។ (RCW 10.118.030)។

# ការស៊ើបអង្កេត និងការត្រួតពិនិត្យលើការប្រើកម្លាំង

(1) សម្រាប់ហេតុការណ៍ដែលបណ្តាលឱ្យស្លាប់ របួសរាងកាយធ្ងន់ធ្ងរឬរបួសយ៉ាងដំណំ អង្គភាពអនុវត្តន៍ច្បាប់ត្រូវតែទាក់ទងភ្លាមៗទៅ Office of Independent Investigations (ការិយាល័យស៊ើបអង្កេតឯករាជ្យ) ដោយអនុលោមតាមនីតិវិធីដែលបង្កើតដោយនាយកអង្គភាព(RCW 43.102.120)។

(2) សម្រាប់ហេតុការណ៍ដែលបណ្តាលឱ្យបុគ្គលណាម្នាក់រងរបួសឬត្អូញត្អែរអំពីរបួស (មិនមែនមិនស្រណុកខ្លួនរយៈពេលខ្លី) ចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យឬស្លាប់ ដោយសារការប្រើកម្លាំងរបស់មន្ត្រីអាជ្ញាធរ នោះប្រធានមន្ត្រីត្រូវជូនដំណឹងភ្លាមៗទៅមន្ត្រីផ្នែកបញ្ជាការដែលសមស្រប។

(3) ប្រធានមន្ត្រីដែលបានប្រើកម្លាំងកាយឬបានឃើញហេតុការណ៍ បានណែនាំ ឬបានបញ្ជាឱ្យប្រើកម្លាំងកាយ មិនត្រូវបំពេញតួនាទីនិងទំនួលខុសត្រូវជាប្រធានមន្ត្រីស៊ើបអង្កេត ឬត្រួតពិនិត្យសម្រាប់ហេតុការណ៍នោះទេ។ នៅពេលស្ថានភាពនេះកើតឡើង ប្រធានមន្ត្រីដែលមិនពាក់ព័ន្ធគួរតែត្រូវបានចាត់តាំងឱ្យបំពេញតួនាទីនិងទំនួលខុសត្រូវជាប្រធានមន្ត្រីស៊ើបអង្កេត ឬត្រួតពិនិត្យ។

(4) <u>ទំនួលខុសត្រូវរបស់ប្រធានមន្ត្រី៖ ការស៊ើបអង្កេត</u>

ពេលទទួលបានការជូនដំណឹងអំពីការប្រើកម្លាំងកាយ ប្រធានមន្ត្រីត្រូវឆ្លើយតបភ្លាមៗទៅកន្លែងកើតហេតុ ប្រសិនបើអាចធ្វើទៅបានដោយសមហេតុផល និងធ្វើការស៊ើបអង្កេតសមស្រប លើកលែងតែនៅពេលដែលប្រធានមន្ត្រីទទួលបានការជូនដំណឹងអំពីការប្រើកម្លាំងកាយកម្រិតស្រាល។ ទោះជាកម្លាំងកាយកម្រិតស្រាលត្រូវមានការកត់ត្រាទុកនិងត្រួតពិនិត្យក៏ដោយ ក៏ប្រធានមន្ត្រីមិនចាំបាច់ឆ្លើយតបទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេតដែរ នៅពេលដែលកម្លាំងកាយកម្រិតស្រាលគឺជាកម្លាំងតែមួយគត់ដែលត្រូវបានប្រើក្នុងអំឡុងហេតុការណ៍។

សម្រាប់ការប្រើកម្លាំងកាយដែលខ្លាំងជាងកម្លាំងកាយកម្រិតស្រាល ប្រសិនបើប្រធានមន្ត្រីមិនអាចឆ្លើយតបទៅទីតាំងនោះបានភ្លាមៗទេ គាត់នឹងត្រូវកត់ត្រាទុកអំពីមូលហេតុ។

សម្រាប់ហេតុការណ៍ដែលមិនពាក់ព័ន្ធនឹងកម្លាំងគ្រោះថ្នាក់ដល់ជីវិត ប្រធានមន្ត្រីទទួលខុសត្រូវលើការអនុវត្តជំហានខាងក្រោម៖

(a) រក្សាសន្តិសុខ និងគ្រប់គ្រងកន្លែងកើតហេតុ។

(b) ធានាថាភាគីរងរបួសទាំងអស់ទទួលបានជំនួយវេជ្ជសាស្ត្រទាន់ពេល។

(c) កំណត់អត្តសញ្ញាណមន្ត្រីអាជ្ញាធរទាំងអស់ដែលជាប់ពាក់ព័ន្ធក្នុងហេតុការណ៍ បានឃើញហេតុការណ៍ ឬបានស្ថិតនៅកន្លែងកើតហេតុ នៅពេលដែលហេតុការណ៍បានកើតឡើង។ ពិភាក្សាអំពីកាលៈទេសៈទូទៅនៃហេតុការណ៍ជាមួយមន្ត្រីអាជ្ញាធរដែលជាប់ពាក់ព័ន្ធ និងមន្ត្រីឃើញហេតុការណ៍ ទៅតាមការអនុញ្ញាត និងធានាបញ្ចប់របាយការណ៍យ៉ាងយូរត្រឹមពេលបញ្ចប់វេនរបស់ខ្លួន លុះត្រាតែស្ថិតក្នុងកាលៈទេសៈដែលអាចយោគយល់ ដូចជាមន្ត្រីណាម្នាក់រងរបួសជាដើម ទើបអាចមិនធ្វើដូច្នេះបាន។

(d) ព្យាយាមសួរចម្លើយបុគ្គលរងការប្រើកម្លាំងកាយពាក់ព័ន្ធនឹងការប្រើកម្លាំងកាយ និងថតការសួរចម្លើយប្រសិនបើអាចដោយគោរពដល់សិទ្ធិមិននិយាយស្តីរបស់គាត់។

(e) កំណត់អត្តសញ្ញាណសាក្សីជាជនស៊ីវិល។ ប្រធានមន្ត្រីមិនត្រូវឃុំឃាំងឬពន្យារពេលសាក្សីដែលបដិសេធមិនបន្តនៅកន្លែងកើតហេតុទេ ទោះយ៉ាងណា ភិនភាគ ព័ត៌មានទំនាក់ទំនង ឯកសារសម្គាល់ខ្លួនផ្សេងទៀតរបស់សាក្សីនោះ (ឧ. ប័ណ្ណបើកបរ) ប្រសិនបើដឹង និងអំណះអំណាងណាមួយពីសាក្សីត្រូវកត់ត្រាទុក។

(f) កត់ត្រាទុកអំពីរបួស និងការសង្គ្រោះបឋមដែលបានផ្តល់ឬបដិសេធ។

(g) ថតរូបរបួស ឬការអះអាងថាមានរបួសទាំងអស់ រួមទាំងបុគ្គលរងការប្រើកម្លាំងនិងមន្ត្រីអាជ្ញាធរទាំងឡាយដែលមានរបួស។

(h) នៅពេលដែលអាចធ្វើបាន ថតកន្លែងកើតហេតុឱ្យឃើញពន្លឺ អាកាសធាតុ កន្លែងដាក់យានជំនិះ ទីតាំងការពារខ្លួន ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

(i) ប្រសិនបើមន្ត្រីអាជ្ញាធរស្លៀកពាក់ដោយមានបំពាក់កាមេរ៉ាជាប់ខ្លួន ត្រូវយកនិងត្រួតពិនិត្យវីដេអូពាក់ព័ន្ធនឹងហេតុការណ៍ដែលប្រើកម្លាំងកាយ។

(j) ធ្វើឱ្យប្រាកដថា ភស្តុតាងទាំងអស់ពាក់ព័ន្ធនឹងការប្រើកម្លាំងកាយត្រូវបានដែកខុសត្រូវ ប្រមូល និងកត់ត្រាទុក។

   i. រកវីដេអូពីភាគីទីបីដែលប្រហែលជាបានថតហេតុការណ៍នោះ រួមមានកាមេរ៉ាសុវត្ថិភាព និងកាមេរ៉ានៅផ្ទះឯកជនក្នុងតំបន់នោះ កត់ត្រាទុកទីតាំង និងព្យាយាមយកវីដេអូនោះ។ ប្រសិនបើមិនអាចមើលឬយកបានទេ ត្រូវកត់ត្រាទុកមូលហេតុ។ ប្រសិនបើរកមិនឃើញទេ ត្រូវកត់ត្រាទុកថារកមិនឃើញទេ។

   ii. សម្រាប់ការប្រើអាវុធ ECW ត្រូវប្រមូលសំបកគ្រាប់ ផ្លែព្រួញ តម្រុយ និងច្បាប់ចម្លងនៃការទាញយកទិន្នន័យអាវុធ ECW។

(k) កំណត់អត្តសញ្ញាណបុគ្គលិកវេជ្ជសាស្ត្រដែលបានវាយតម្លៃ ឬបានផ្តល់ជំនួយវេជ្ជសាស្ត្រដល់បុគ្គលនោះ ឬមន្ត្រីអាជ្ញាធរ។

(l) រាល់ការប្រព្រឹត្តខុសឆ្គង ឬអាចជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ត្រូវរាយការណ៍ភ្លាមៗទៅមន្ត្រីផ្នែកបញ្ជាការដែលសមស្រប។

(5) <u>ទំនួលខុសត្រូវរបស់ប្រធានមន្ត្រី៖ ត្រួតពិនិត្យ</u>

(a) ប្រធានមន្ត្រីត្រូវត្រួតពិនិត្យឯកសារនិងភស្តុតាងអំពីហេតុការណ៍ទាំងអស់ឱ្យបានទាន់ពេល ដើម្បីធានាថាមានភាពពេញលេញ ត្រឹមត្រូវ និងទាន់ពេលវេលា។ ប្រធានមន្ត្រីត្រូវកត់ត្រាទុកសកម្មភាពដែលពួកគេបានធ្វើអំឡុងពេលត្រួតពិនិត្យ (ឧ. ការត្រួតពិនិត្យរបាយការណ៍ដែលមានទាំងអស់ វីដេអូថតដោយអង្គភាព វីដេអូពីភាគីទីបី អំណះអំណាងពីសាក្សី រូបថត ការសង្កេត ឬព័ត៌មានស៊ើបអង្កេតផ្សេងទៀត)។

(b) ប្រធានមន្ត្រីត្រូវបញ្ជូនរបាយការណ៍ការប្រើកម្លាំងដែលមិនពេញលេញឬមិនគ្រប់គ្រាន់ទៅវិញ ដើម្បីស្នើសុំការបញ្ជាក់ ឬព័ត៌មានលម្អិតបន្ថែម។

(c) ប្រធានមន្ត្រីត្រូវផ្តល់អនុសាសន៍បឋមជាលាយលក្ខណ៍អក្សរ ថាតើការប្រើកម្លាំងបានអនុលោមតាមគោលការណ៍អង្គភាពឬអត់។ ប្រធានមន្ត្រីក៏ត្រូវកំណត់គោលការណ៍ ការបណ្តុះបណ្តាល យុទ្ធសាស្ត្រ ការមើលការខុសត្រូវ ការរៀបចំផែនការនិងការសម្របសម្រួល ជម្រើសប្រើកម្លាំង ឧបករណ៍ ព្រមទាំងការប្រព្រឹត្តក្រោយហេតុការណ៍និងបញ្ហាប្រតិបត្តិការដែលកើតឡើងដោយសារហេតុការណ៍នោះ ហើយកត់ត្រាទុកក្តីកង្វល់និងអនុសាសន៍ទាំងនេះ។

(d) ប្រធានមន្ត្រីត្រូវបញ្ចប់ការត្រួតពិនិត្យការប្រើកម្លាំងឱ្យទាន់ពេលវេលា ហើយផ្តល់ការវាយតម្លៃ ព្រមទាំងរបាយការណ៍និងការស៊ើបអង្កេតអំពីការប្រើកម្លាំង សម្រាប់ការត្រួតពិនិត្យការបញ្ជាជាបន្តបន្ទាប់។

(6) <u>ការត្រួតពិនិត្យការបញ្ជា</u>

(a) អ្នកត្រួតពិនិត្យគ្រប់រូបក្នុងឋានានុក្រមនៃការបញ្ជាជាអ្នកទទួលខុសត្រូវចំពោះការធានានូវភាពត្រឹមត្រូវ ភាពពេញលេញ និងភាពទាន់ពេលវេលានៃរបាយការណ៍ និងការស៊ើបអង្កេតអំពីការប្រើកម្លាំង។ អ្នកត្រួតពិនិត្យនីមួយៗត្រូវកត់ត្រាទុកមតិយោបល់របស់ខ្លួន ថាតើការប្រើកម្លាំងកាយបានអនុលោមតាមគោលការណ៍អង្គភាពឬអត់ ហើយកំណត់គោលការណ៍ ការបណ្តុះបណ្តាល យុទ្ធសាស្ត្រ ឧបករណ៍ ឬបញ្ហាក្រោយហេតុការណ៍ដែលកើតឡើងដោយសារហេតុការណ៍នោះ ហើយកត់ត្រាទុកក្តីកង្វល់និងអនុសាសន៍របស់ពួកគេ។

(b) ចុងក្រោយ ប្រធានអង្គភាពឬបុគ្គលទទួលការចាត់តាំងត្រូវកំណត់ថាតើការប្រើកម្លាំងកាយបានអនុលោមតាមគោលការណ៍អង្គភាពឬអត់ ហើយធ្វើឱ្យប្រាកដថាគោលការណ៍ ការបណ្តុះបណ្តាល យុទ្ធសាស្ត្រ ការមើលការខុសត្រូវ ការរៀបចំផែនការនិងការសម្របសម្រួល ជម្រើសប្រើកម្លាំង ឧបករណ៍ ព្រមទាំងការប្រព្រឹត្តក្រោយហេតុការណ៍និងបញ្ហាប្រតិបត្តិការដែលកើតឡើងដោយសារហេតុការណ៍នោះត្រូវបានដោះស្រាយ។

(c) ត្រូវប្រាកដថាកត់ត្រាទុក និងស៊ើបអង្កេតរាល់បណ្តឹងតវ៉ាពីបុគ្គលរងការប្រើកម្លាំងកាយឬបុគ្គលផ្សេងទៀតអំពីការប្រព្រឹត្តខុសឆ្គង ដោយយោងតាមនីតិវិធីសម្រាប់បណ្តឹងតវ៉ារបស់អង្គភាព។

(d) មន្ត្រីផ្នែកបញ្ជាការត្រូវធ្វើការជូនដំណឹង និងណែនាំបន្តសមស្រប ប្រសិនបើការត្រួតពិនិត្យការប្រើកម្លាំងបង្ហាញថាមានការចោទប្រកាន់ពីបទប្រព្រឹត្តឧក្រិដ្ឋកម្ម ឬការបំពានគោលការណ៍ រួមទាំងរាយការណ៍ទៅ Criminal Justice Training Commission (គណៈកម្មការបណ្តុះបណ្តាលផ្នែកយុត្តិធម៌ឧក្រិដ្ឋកម្ម) ដែលតម្រូវដោយក្រម RCW 43.101.135។

(7) <u>ការត្រួតពិនិត្យការបណ្តុះបណ្តាល</u>

គ្រូបណ្តុះបណ្តាលរបស់អង្គភាពត្រូវត្រួតពិនិត្យរបាយការណ៍ការប្រើកម្លាំងទាំងអស់ ដើម្បីកំណត់និន្នាការ និងណែនាំការអភិវឌ្ឍការបណ្តុះបណ្តាលក្នុងសេវាកម្ម។

(8) <u>ការស៊ើបអង្កេតរដ្ឋបាលលើកម្លាំងគ្រោះថ្នាក់ដល់ជីវិត</u>

ដោយឡែក និងខុសពីការស៊ើបអង្កេតបទឧក្រិដ្ឋលើមន្ត្រីអាជ្ញាធរដែលជាប់ពាក់ព័ន្ធនឹងហេតុការណ៍ប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិតដែលធ្វើឡើងដោយ Office of Independent Investigations (ការិយាល័យស៊ើបអង្កេតឯករាជ្យ) ដែលបង្កើតដោយជំពូកទី 43.102 RCW ឬ Independent Investigative Team (ក្រុមស៊ើបអង្កេតឯករាជ្យ) ដែលបង្កើតដោយ Washington Administrative Code (WAC, ក្រមរដ្ឋបាលនៃរដ្ឋវ៉ាស៊ីនតោន) 139-12, ក្រោយពេលស៊ើបអង្កេតបទឧក្រិដ្ឋ អង្គភាពជាប់ពាក់ព័ន្ធត្រូវធ្វើការស៊ើបអង្កេតរដ្ឋបាល និងត្រួតពិនិត្យហេតុការណ៍ប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិតឱ្យទាន់ពេលវេលា ដើម្បីកំណត់ថាមានការអនុលោមតាមគោលការណ៍ និងនីតិវិធីរបស់អង្គភាពឬអត់ ហើយកំណត់តម្រូវការសម្រាប់ការបណ្តុះបណ្តាល។ នៅពេលបញ្ចប់ការស៊ើបអង្កេតរដ្ឋបាល អង្គភាពជាប់ពាក់ព័ន្ធគួរតែកោះប្រជុំ Serious Incident Review Board (ក្រុមប្រឹក្សាត្រួតពិនិត្យហេតុការណ៍ធ្ងន់ធ្ងរ)។

## Serious Incident Review Board

អង្គភាពអនុវត្តន៍ច្បាប់នីមួយៗគួរតែរក្សា Serious Incident Review Board (ក្រុមប្រឹក្សាត្រួតពិនិត្យហេតុការណ៍ធ្ងន់ធ្ងរ) ដើម្បីត្រួតពិនិត្យហេតុការណ៍ធ្ងន់ធ្ងរ រួមទាំងការប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិតនីមួយៗ និងហេតុការណ៍ដែលបុគ្គលណាម្នាក់ស្លាប់ក្នុងពេលជាប់ឃុំ។ គោលបំណងនៃការត្រួតពិនិត្យនេះគឺវាយតម្លៃឱ្យបានច្បាស់អំពីហេតុការណ៍ដើម្បី (1) ប្រាកដថាមន្ត្រីអាជ្ញាធរបានប្រើសិទ្ធិអំណាចរបស់ខ្លួនដោយស្របច្បាប់ និងស្របតាមការរំពឹងទុក ការបណ្តុះបណ្តាល និងគោលការណ៍របស់អង្គភាព ហើយ (2) កំណត់ថាត្រូវមានការបណ្តុះបណ្តាល ឬកែប្រែគោលការណ៍ឬអត់។

ដំណើរការត្រួតពិនិត្យផ្ទៃក្នុងនេះគួរតែបន្ថែមពីលើការស៊ើបអង្កេតផ្សេងទៀតដែលធ្វើឡើងដោយ Office of Independent Investigations, Independent Investigative Team ឬអង្គភាពខាងក្រៅផ្សេងទៀតដែលមានដែនសមត្ថកិច្ចលើការស៊ើបអង្កេត ឬវាយតម្លៃហេតុការណ៍នេះ។

Serious Incident Review Board អាចត្រូវបានកុំប្រជុំដើម្បីត្រួតពិនិត្យកាលៈទេសៈជុំវិញការប្រើកម្លាំងកាយទៅតាមការសម្រេចរបស់ថ្នាក់ដឹកនាំអង្គភាព។

(1) **សមាសភាព**

ក្នុងករណីអាចទៅរួច ក្រុមប្រឹក្សានេះគួរតែមានយ៉ាងតិច៖

(a) ប្រធានអង្គភាព ឬអ្នកទទួលការចាត់តាំងជាន់ខ្ពស់ពីប្រធានអង្គភាព

(b) សមាជិកមន្ត្រីផ្នែកបញ្ជាការម្នាក់ទៀត ឬអ្នកទទួលការចាត់តាំងដែលមិនពាក់ព័ន្ធនឹងហេតុការណ៍នោះ

(c) មន្ត្រីបណ្ដុះបណ្ដាល និង

(d) សមាជិកសហគមន៍មកពីដែនសមត្ថកិច្ចក្នុងតំបន់ដែលមិនមែនជាមន្ត្រីអាជ្ញាធរ។

(2) **វិសាលភាព និងទំនួលខុសត្រូវ**

ដោយពិចារណាលើអំណះអំណាង ការសួរចម្លើយ របាយការណ៍ និងភស្តុតាងទាំងអស់ពីហេតុការណ៍ Serious Incident Review Board មានភារកិច្ចវាយតម្លៃទិដ្ឋភាពទាំងអស់នៃហេតុការណ៍ និងផ្តល់អនុសាសន៍ដោយគិតលើយុទ្ធសាស្ត្រ ការបណ្ដុះបណ្ដាល គោលការណ៍ និងឧបករណ៍។

ផ្នែកដែលក្រុមប្រឹក្សានេះគួរតែពិចារណារួមមានជាអាទិ៍៖

(a) ការសម្រេចចិត្តតាមយុទ្ធសាស្ត្រ រួមមានការប្រាស្រ័យទាក់ទង និងការរៀបចំផែនការ មុនពេលប្រើកម្លាំងកាយ

(b) កម្រិតដែលមន្ត្រីអាជ្ញាធរបានប្រើយុទ្ធសាស្ត្របន្ថយភាពតានតឹង

(c) ប្រសិទ្ធភាពនៃការមើលការខុសត្រូវពីចម្ងាយ ឬនៅកន្លែងកើតហេតុ

(d) ប្រសិទ្ធភាពនៃការទាក់ទងតាមវិទ្យុ (រួមទាំងអ្នកបញ្ជូនសារ)

(e) ប្រសិទ្ធភាព និងឧបករណ៍សមស្របដែលមានប្រើ

(f) ថាតើគោលការណ៍បច្ចុប្បន្នបានផ្តល់ការណែនាំគ្រប់គ្រាន់ដល់មន្ត្រីអាជ្ញាធរដែលជាប់ពាក់ព័ន្ធឬអត់

(g) ថាតើការបណ្ដុះបណ្ដាលបច្ចុប្បន្នមានភាពគ្រប់គ្រាន់ ដើម្បីឱ្យមន្ត្រីអាជ្ញាធរត្រៀមខ្លួនសម្រាប់កាលៈទេសៈចំពោះមុខ

(h) ការសម្រេចចិត្តក្រោយហេតុការណ៍ រួមទាំងប្រសិទ្ធភាពដែលមន្ត្រីអាជ្ញាធរនៅកន្លែងកើតហេតុបានប្ដូរទៅប្រើជម្រើសសង្គ្រោះ និងបានផ្តល់ឬបានសម្របសម្រួលដល់ការសង្គ្រោះបឋម។

(i) ការប្រាស្រ័យទាក់ទងជាមួយអ្នកជំនាញថែទាំសុខភាព [ឧ. Emergency Medical Technicians (EMT, អ្នកជំនាញសង្គ្រោះបន្ទាន់) ជំនួយការគ្រូពេទ្យ]

(j) ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងជាមួយគ្រួសារបុគ្គលរងរបួស ដើម្បីជូនដំណឹងដល់ពួកគេអំពីហេតុការណ៍

(k) ប្រតិបត្តិការមើលការខុសត្រូវក្រោយពេលប្រើកម្លាំង រួមទាំងការរក្សាភស្តុតាង និងការកំណត់អត្តសញ្ញាណសាក្សី និង

(l) គុណភាពនៃរបាយការណ៍អំពីហេតុការណ៍

(3) **កិច្ចការត្រូវសម្រេច**

(a) Review Board គួរតែមាននីតិវិធីដំណើរការផ្លូវការ ដើម្បីកត់ត្រាទុក អនុវត្ត និងតាមដានអនុសាសន៍ទាំងអស់ ក៏ដូចជាកិច្ចការត្រូវសម្រេចដែលកើតចេញពីកិច្ចពិភាក្សារបស់ក្រុមប្រឹក្សានេះ ដោយផ្តល់តម្លាភាពដល់សាធារណជន នៅពេលដែលអាចទៅរួច។

(b) នៅពេលបញ្ចប់កិច្ចប្រជុំរបស់ Review Board ម្តងៗ ក្រុមប្រឹក្សានេះគួរតែចាត់តាំងសមាជិកម្នាក់ឱ្យសួរចម្លើយមន្ត្រីអាជ្ញាធរដែលជាប់ពាក់ព័ន្ធ មន្ត្រីអាជ្ញាធរជាសាក្សី និងប្រធានមន្ត្រីនៅកន្លែងកើតហេតុ ពាក់ព័ន្ធនឹងបញ្ហាទាំងអស់ដែលបានកំណត់ដោយ Review Board។

(c) Review Board គួរតែប្រាស្រ័យទាក់ទងអំពីមេរៀនដែលមន្ត្រីអង្គភាពទាំងអស់បានរៀន។

# សវនកម្មដោយឯករាជ្យលើហេតុការណ៍ប្រើកម្លាំង និងដំណើរការត្រួតពិនិត្យការប្រើកម្លាំង

អង្គភាពគួរតែពិចារណាជួលសវនករឯករាជ្យ ដើម្បីត្រួតពិនិត្យហេតុការណ៍ប្រើកម្លាំងគ្រោះថ្នាក់ដល់ជីវិត និងរបួសរាងកាយធ្ងន់ធ្ងរ ដែលបង្កឱ្យមានក្ដីកង្វល់ទាំងក្នុង និងក្រៅអង្គភាព។ អង្គភាពក៏គួរតែពិចារណាជួលសវនករឯករាជ្យជាប្រចាំ ដើម្បីត្រួតពិនិត្យកម្រិតនៃគោលការណ៍ប្រើកម្លាំងរបស់អង្គភាពផងដែរ ហើយការរំពឹងទុកពាក់ព័ន្ធនឹងការប្រើកម្លាំងដោយមន្ត្រីអាជ្ញាធររបស់ខ្លួនកំពុងត្រូវបានអនុវត្តតាមរយៈការបណ្ដុះបណ្ដាល និងដំណើរការត្រួតពិនិត្យការប្រើកម្លាំងរបស់អង្គភាព។ ការរកឃើញ និងអនុសាសន៍របស់សវនករឯករាជ្យគួរតែកត់ត្រាទុកក្នុងរបាយការណ៍សាធារណៈ។

អង្គភាពគួរតែផ្ដល់សិទ្ធិចូលមើលឯកសារពាក់ព័ន្ធទាំងអស់ដោយសេរីដល់សវនករឯករាជ្យដែលធ្វើការត្រួតពិនិត្យនេះ។